អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

ឯកសារដើម

ORIGINAL/ORIGINAL

ថ្ងៃ ខែ ឆ្នាំ (Date): 25-Jan-2017, 15:20

CMS/CFO: Sann Rada

# **កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

## **ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ**

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៤នាទី**

**សវនាការលើកទី៤៨០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ស្ដាវរូឡា ប៉ាប៉ាដូពូឡូស

*(Ms. Stavroula PAPADOPOULOS)*

លោកស្រី សែ កុលវុឌ្ឍី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល

(Mr. Vincent de wilde d'ESTMAEL)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(Mr.Victor KOPPE)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉ែន ពៅ

លោក ហុង គឹមសួន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក វ៊ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី៖** 2-TCCP-235

សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល ផ្ដើមពី................................................ ទំព័រ ៣
សួរដោយលោក គង់ សំអុន ផ្ដើមពី ...................................................................... ទំព័រ ១២

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-235 បញ្ចប់។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះ គឺដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-235 ដើមបណ្តឹងមានវត្តមានរួចហើយនៅបន្ទប់សវនាការនេះ ហើយនៅថ្ងៃនេះ មិនមានសាក្សីបម្រុងនោះទេ។

សូមអរគុណលោកប្រធាន។

[០៩:០៦:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយសារគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាព

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈឈឺចង្កេះរ៉ាំរ៉ៃ អង្គុយយូរមិនបានស្ពឹកជើងតិចតួច និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។

[០៩:០៧:២០]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី ហើយសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាមានរយៈពេល៣០នាទីក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និង ភាគីទាំងអស់។ ជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី។

លោកប្រធាន ខ្ញុំគិតថា ខ្ញុំនៅសល់៤០នាទី ព្រោះថាម្សិលមិញ គាត់ចាប់ផ្តើមនៅម៉ោងពីរ ដប់នាទី ទៅហើយ។

អ៊ីចឹងខ្ញុំព្យាយាមសួរឲ្យបានខ្លី។

[០៩:០៨:១៥]

**បន្តការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី សូមលោកស្ដាប់សំណួរខ្ញុំឲ្យបានច្បាស់ ហើយសូមឲ្យលោកឆ្លើយខ្លីៗជាងពីម្សិលមិញទៅបានហើយ កុំឆ្លើយវែងៗពេក។ កាលពីម្សិលមិញ យើងបាននិយាយគ្នាអំពីការប្រជុំមួយនៅភ្នំពេញ ដែលលោកបានចូលរួម។ គេបញ្ជូនលោកពីកោះកុងទៅប្រជុំនៅភ្នំពេញ ហើយពេលនោះ នួន ជា ធ្វើបទឧទ្ទេសនាម ហើយគាត់នៅអង្គុយជិត តាម៉ុក និង សុន សេន។ ហើយលោកបាននិយាយថា លោកចាំថា នួន ជា បាននិយាយថា បក្សជឿជាក់លើយើងទាំងអស់គ្នា ហើយយើងត្រូវធ្វើយ៉ាងម៉េចកុំឲ្យខ្មាំងយួនហ្នឹង លុកលុយចូលមកប្រទេសបាន។ តើ នួន ជា ឬក៏ តាម៉ុក មានបានប្រាប់លោកទាំងអស់គ្នាថា លោកទាំងអស់គ្នាហ្នឹងជាយុទ្ធជនខ្មែរហ្នឹងគឺថា មានកម្លាំងខ្លាំងក្លាជាងពួកវៀតណាមទេ?

**2-TCCP-235៖**

**ឆ៖** បាទ រឿងនេះជាការពិត ដែលគាត់លើកឡើង។

**ស៖** ចុះគាត់មានបាននិយាយថា ខ្មែរម្នាក់ហ្នឹង អាចវាយបានជាមួយនឹងវៀតណាម៣០នាក់ទេ?

[០៩:០៩:៤៥]

**ឆ៖** គាត់អត់បាននិយាយទេ កាលនោះ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី កាលពីម្សិលមិញលោកថាលោកត្រូវបានគេចាប់ខ្លួន ហើយធ្វើទារុណកម្ម<នៅលើទូកមួយ> ក៏ប៉ុន្តែក្រោយមកត្រូវបានដោះលែង ហើយឲ្យទៅធ្វើការ។ ពេលលោកទៅសមរភូមិខាងបូព៌ា តើលោកមានគិតថាចម្លែកទេ ដែលគេឲ្យលោកចូលក្នុងកងទ័ពខ្មែរក្រហមដើម្បីទៅសមរភូមិនៅបូព៌ាហ្នឹង?

**ឆ៖** ខ្ញុំគិតស្មានមិនដល់ថាដល់ថ្នាក់គេបញ្ជូនឲ្យខ្ញុំទៅច្បាំងហ្នឹង ខ្ញុំនឹកឃើញថាគេបញ្ជូនខ្ញុំទៅដាក់គុកបន្តទៀត ឬមួយយ៉ាងណានោះ ក៏ខ្ញុំគិតថាអីចឹង មិនបានគិតថាឲ្យទៅច្បាំងជាមួយវៀតណាមទេបាទ។

**ស៖** តើអ្នកចូលរួមក្នុងការប្រជុំនោះមានជម្រើសថាខ្លួនចូលធ្វើជាយោធា -- កងទ័ព ឬក៏មិនចូលធ្វើបាន ហើយសម្រេចថាមិនទៅសមរភូមិអីបានទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពេលនោះគឺមិនអាចសម្រេចថាមិនទៅទេបាទ។

**ស៖** កាលពីម្សិលមិញលោកថា ក្នុងចំណោមអ្នកចូលរួមប្រជុំ ដែលដឹកនាំដោយ នួន ជា ហ្នឹងគឺថាមានជាង ១.០០០នាក់ ហើយលោកថា ៤០០នាក់ ក្នុងចំណោមនោះ ក្នុងនោះមានលោកផងដែរ ត្រូវបានគេដាក់ឲ្យស្ថិតនៅក្រោមបង្គាប់របស់ តាពីន។ ខ្ញុំចង់ដឹងថាតើកន្លែងដែលគេចាត់តាំងឲ្យលោកទៅធ្វើការក្រោមបញ្ជារបស់ តាពីន ហ្នឹង ស្ថិតនៅក្រោម ស្ថិតនៅក្នុងតំបន់អី ភូមិភាគអីដែរ?

[០៩:១២:០៩]

**ឆ៖** បើគេបញ្ជូនទៅនោះគឺថា ទៅតំបន់ភូមិភាគបូព៌ា។ ភូមិភាគបូព៌ាបានន័យថាខេត្តកំពង់ចាម ហើយទៅដល់កន្លែងតាពីន មិនមែនតាពិន ទេ តាពីន ឈ្មោះគេ តាពីន បាទ។ ជាអគ្គបញ្ជាការរង អគ្គសេនាធិការរងបាទ។

**ស៖** កាលពីម្សិលមិញលោកថា សុន សេន ជានាយសេនាធិការមកទីនុ៎ង ហើយមានយកសម្ភារមកផងដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលហ្នឹងតើគាត់ប្រគល់សម្ភារអ្វីខ្លះ? ហើយពេលហ្នឹងគេមានបានឲ្យលោកកាន់អាវុធទេ?

**ឆ៖** បាទ ទៅដល់កន្លែងអគ្គសេនាធិការរងហ្នឹងហើយ កន្លែងតាពីន ហ្នឹង ពេលនោះម៉ោងប្រហែលជាប្រាំបួន ទៅដប់ព្រឹក សុន សេន ហើយនិងទីប្រឹក្សាចិនពីរនាក់ សុន សេន ហើយនិងអង្គរក្សរបស់គាត់ជាច្រើនឡានទៅដល់។ ទៅដល់ ក៏គាត់រៀបចំចាត់ចែងជាក្រុមជាកងទៅតាមលំដាប់ថ្នាក់គេហ្នឹងបាទ។

**ស៖** អាវុធដែលលោកទទួលបានហ្នឹង ជាអាវុធប្រភេទណាដែរ?

**ឆ៖** អាវុធមានតែអាវុធអាកាចិន ហើយនិងចម្រុះកាលនោះបាទ មានកាំភ្លើងធំតូច អាសេវេនធីណៃ កាំភ្លើងអាអ៊ែ១៥ របស់សហរដ្ឋអាមេរិកហ្នឹង ចម្រុះបាទ *(ឮមិនច្បាស់)*។ តែដូចជាដោយឡែកមេៗគេ គេទៅប្រគល់កាំភ្លើងខ្លី ឬកាំភ្លើងខ្លីមួយដើម កាំភ្លើងវែងមួយដើមបាទ។

**ស៖** លោកថា គេបានបង្កើតជាក្រុម ហើយអ៊ីចឹងខ្ញុំចង់ដឹងថាលោកស្ថិតនៅក្រុមណា កងណា ហើយលោកមានតួនាទីអ្វីនៅក្នុងក្រុមនុ៎ង?

**ឆ៖** ខ្ញុំនៅកងអនុសេនាធំលេខ១ ជាមេបញ្ជាការរង។ នៅកងអនុសេនាធំ គឺមានគ្នាប្រហែលជា២០០នាក់ ដែលខ្ញុំ និងមេបញ្ជាការហ្នឹង គ្រប់គ្រងបាទ។

**ស៖** តើលោកធ្លាប់ចូលរួមវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមទេ?

**ឆ៖** បាទ ក្រោយពេលគេបំពាក់អាវុធ មានកងរថក្រោះរថអីហ្នឹង គឺឡើងចូលសមរភូមិទាំងយប់ហ្នឹងតែម្តង។

[០៩:១៦:១៤]

**ស៖** <ខ្ញុំជឿថា លោកបាននិយាយថា លោកបានទៅដល់នៅក្នុងឆ្នាំ១៩៧៧។> នៅឆ្នាំ៧៧ <និង> ៧៨ តើលោកមានបានចូលរួមក្នុងការវ៉ៃវៀតណាមទៅដល់ទឹកដីវៀតណាមទេ?

**ឆ៖** បាទ កាលគ្រាដំបូង គឺវៀតណាម កងទ័ពវៀតណាមហ្នឹង គឺគាត់បោះទីតាំងនៅម្តុំក្រែក។ ដល់ពួកខ្ញុំវាយបុកធ្លាក់ទៅដល់មេមត់ បោះទីតាំងនៅមេមត់ទៀត។ ដល់ពេលវាយបែកមេមត់ហើយ វាក៏ទៅបោះទីតាំងនៅតាមព្រំដែន។ ព្រំដែនវាហ្នឹង គឺខេត្តតៃនិញនៅជាប់ហ្នឹង វាទៅបោះទីតាំងទឹកដីរបស់វាហ្នឹង។ ហើយពេលនោះ ក៏មានការត្រៀម ហើយពួកខ្ញុំមួយចំនួនត្រូវ សុន សេន គាត់ចាត់តាំងឲ្យចូលលុកនៅក្នុងប្រទេសវៀតណាមហ្នឹង។

**ស៖** នៅក្នុង<ភូមិភាគ លោកឈរជើង>នៅពញាក្រែក មេមត់ នៅភូមិភាគបូព៌ាក្នុងខេត្តកំពង់ចាម នៅកន្លែងដែលលោកប្រចាំការហ្នឹង តើមានជនស៊ីវិលវៀតណាម ដែលត្រូវបានកងទ័ពខ្មែរក្រហមដែលចាប់ខ្លួនទេ ទាំងនៅក្នុងទឹកដីខ្មែរ និងទឹកដីវៀតណាមនោះ?

**ឆ៖** នៅពេលដែលខ្ញុំត្រឡប់មកវិញ ក៏មានឃើញការចាប់បងប្អូនប្រជាជនមួយចំនួនដែរបាទ។

**ស៖** លោកដឹងទេថា ក្រោយពេលចាប់ហើយហ្នឹង គេបញ្ជូនអ្នកទាំងអស់ហ្នឹងទៅណាដែរ ហើយពួកគាត់ទទួលរងនូវជោគវាសនាបែបណាដែរ?

**ឆ៖** ការចាប់បញ្ជូនរបស់គេនេះ គឺបញ្ជូនមកកន្លែងអគ្គសេនាធិការ។ តា សុន សេន ឬក៏ តាពីនហ្នឹង ហើយគេមានធ្វើគុក ធ្វើអាកន្លែងខ្នោះជើងខ្នោះដៃ ដាក់បងប្អូនប្រជាជន ដែលពួកគេមានការសង្ស័យនោះ ហើយបន្ទាប់មក ពេលនោះឃើញតាពីន, សុន សេន ហ្នឹង គឺបានសម្រេចបញ្ជូនឲ្យទៅតាមមូលដ្ឋានវិញ។ មិនដឹងថា ទៅមូលដ្ឋាន កន្លែង តំបន់ ស្រុកណាទេ គឺគ្រាន់តែគេបញ្ជូនទៅឲ្យកងទ័ពហ្នឹងជូនឡានយកទៅមូលដ្ឋានវិញ។ តែប៉ុណ្ណឹងបាទ។

**ស៖** ចុះឃោធាវៀតណាម ដែលត្រូវបានចាប់ខ្លួននៅក្នុងពេលកម្ពុជាមានជម្លោះជាមួយវៀតណាមនោះ ពេលដែលគេចាប់ខ្លួនបានហើយ តើគេធ្វើយ៉ាងម៉េចចំពោះឃោធាវៀតណាមទាំងអស់ហ្នឹង?

[០៩:២០:៤២]

**ឆ៖** រឿងចាប់កងទ័ពវៀតណាម ឬក៏ប្រជាជនវៀតណាមហ្នឹងគឺ សុន សេន ហាមដាច់ខាតមិន

ឲ្យសម្លាប់ទេ គឺថាធ្វើម៉េចបញ្ជូនឲ្យដល់ទីក្រុងភ្នំពេញបាទ។ អរគុណ។

**ស៖** តើលោកធ្លាប់ស្ដាប់ឮថានៅក្នុងតំបន់ដែលលោកប្រចាំការហ្នឹងថាមានគូចម្រុះជាតិសាសន៍ទេ ដូចជាថាប្ដីខ្មែរ ប្រពន្ធវៀតណាម ឬប្ដីវៀតណាម ប្រពន្ធខ្មែរអ៊ីចឹងណ៎ា ហើយគេមានចេញសេចក្ដីណែនាំអី ចំពោះអ្នកដែលមានប្ដីប្រពន្ធជាជនជាតិវៀតណាមបែបហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ រឿងហ្នឹងបាទ។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើការឲ្យ សុន សេន និង តាពីន នៅភូមិភាគបូព៌ា តើ សុន សេន ហ្នឹងទៅភ្នំពេញហ្នឹងញឹកញាប់ទេ?

**ឆ៖** សុន សេន គាត់ជា -- ក្នុងនាមជាអគ្គបញ្ជាការទូទាំងប្រទេស គឺគាត់ចុះឡើងៗដើរមកសមរភូមិ មកកន្លែងអគ្គសេនាធិការ ហើយចុះឡើងៗគ្រប់ភូមិភាគនិរតី ភូមិភាគបូព៌ាហ្នឹង។ គាត់ឧស្សាហ៍ចុះឡើងៗជារៀងរហូតបាទ។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកគឺ E3/9772 លោកបានឆ្លើយច្បាស់ជាងនេះ គឺនៅចម្លើយទី២ ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

"តាពីន ទទួលខុសត្រូវខាងយោធាទូទាំងប្រទេស ហើយធ្វើការជំនួស សុន សេន កាលណា សុន សេន អវត្តមាន។ ជាឧទាហរណ៍នៅពេលដែល សុន សេន ចូលទៅប្រជុំនៅភ្នំពេញ តាពីន ជាអ្នកទទួលបន្ទុកនៅពេលដែលគាត់អវត្តមាន"។ ចប់សេចក្ដីដកស្រង់។

[០៩:២៣:៣១]

ដូច្នេះក្នុងចម្លើយនេះ លោកដឹងថា សុន សេន ទៅភ្នំពេញ។ អ៊ីចឹងលោកដឹងថា សុន សេន ទៅភ្នំពេញហ្នឹងដោយរបៀបណា ហើយគាត់ទៅហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** គាត់ក្នុងនាមជាមេបញ្ជាការ គាត់តែងតែវិលចុះវិលឡើង ហើយក៏មានអង្គរក្សរបស់គាត់ បីបួនឡាន កុម្មង់ការរបស់ចិន ហើយក៏រួមជាមួយទីប្រឹក្សាចិនផង។ បើយ៉ាងអន់ណាស់ក៏ពីរនាក់ទៅបីនាក់ រឿងអង្គរក្សរបស់គេផ្សេងទៀតបាទ។ ចុះឡើងៗក្រុងភ្នំពេញ ទៅសមរភូមិ។

**ស៖** ពេលដែលលោកប្រចាំការនៅសមរភូមិបូព៌ា តើមានការបោសសម្អាតទ្រង់ទ្រាយធំ ចំពោះកម្មាភិបាលភូមិភាគបូព៌ានេះ ទាំងជនស៊ីវិលនិងយោធាទេ នៅក្នុងចន្លោះឆ្នាំ៧៧ ដល់ ឆ្នាំ៧៨ហ្នឹង? លោកដឹងអ្វីខ្លះពីរឿងបោសសម្អាតនេះ?

**ឆ៖** ព្រោះខ្ញុំក៏មិនសូវបានក្ដាប់បានដែរ ព្រោះខ្ញុំជាអ្នកនៅក្នុងសមរភូមិ។ នៅពេលដែលខ្ញុំត្រូវ

របួសជើងម្ខាងឆ្វេងនេះ ខ្ញុំទៅសម្រាកពេទ្យ។ ខ្ញុំបានឮសួរពួកអ្នកសម្រាកពេទ្យដូចគ្នាហ្នឹងនិយាយពីរឿងការចាប់ចងប្រជាពលរដ្ឋនៅភូមិភាគបូព៌ា រួមទាំងកង -- អតីតកងទ័ពភូមិភាគបូព៌ា ដែលកាលនោះក្ដាប់ដោយ សោ ភឹម នោះ។ ដោយ សោ ភឹម នោះគាត់គឺថាបក្សត្រូវប្រមូល បើមិនយ៉ាងណាក៏ចាប់ដកយកមកក្រោយទាំងអស់កងទ័ពភូមិភាគបូព៌ាហ្នឹង កាលហ្នឹង។

**ស៖** តើលោកធ្លាប់ចូលរួមប្រជុំ ដែលគេនិយាយអំពីការបោសសម្អាតផ្ទៃក្នុង គឺការបោសសម្អាតអ្នកដែលត្រូវបានគេសង្ស័យទេ?

**ឆ៖** បាទ ខ្ញុំមិនបានចូលរួមទេ ផ្នែកខាងការបោសសម្អាតផ្ទៃក្នុងអីនេះ គឺខ្ញុំរួមប្រជុំ គេរួមប្រជុំតែពីរឿងវៃការពារទឹកដី វៃជាមួយយួនហ្នឹង។ តែប៉ុណ្ណឹងបាទ។

**ស៖** នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយដដែល គឺ E3/9772 ចម្លើយទី៨ <និងទី៩> ហ្នឹងគឺមានគួរឲ្យលក្ខណៈគួរឲ្យចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែនៅក្នុងចម្លើយទី១២ ហ្នឹងលោកបានឆ្លើយដូចតទៅ៖

[០៩:២៧:១៨]

"ក្រោយពេល សោ ភឹម ធ្វើអត្តឃាត កម្មាភិបាលនៅភូមិភាគបូព៌ាត្រូវជំនួសដោយកម្មាភិបាលមកពីភូមិភាគនិរតី។ នៅក្នុងអង្គប្រជុំទាំងនោះ ការបោសសម្អាតផ្ទៃក្នុង គឺថា ត្រូវបានលើកយកមកពិភាក្សា ក៏ប៉ុន្តែពាក្យថា បោសសម្អាតផ្ទៃក្នុងហ្នឹង គឺថា មិនបាននិយាយឲ្យបានច្បាស់ទេ ពួកគេគ្រាន់តែនិយាយថា ពួកគេត្រូវកំណត់រកឲ្យឃើញអ្នកដែលចូលរួមជាមួយនឹងវៀតណាម ហើយគេនឹងរៀបចំមូលដ្ឋានឡើងវិញ"។ បញ្ចប់ការដកស្រង់។

ដូច្នេះក្នុងការប្រជុំដែលលោកបានចូលរួមនោះ លោកបាននិយាយថា គេនិយាយអំពីការបោសសម្អាតផ្ទៃក្នុង និងការកំណត់អត្តសញ្ញាណអ្នកណាដែលចូលដៃជើងជាមួយវៀតណាម។ លោកសាក្សីលោកអាចបញ្ជាក់ម្ដងទៀតបានទេ លោកពិតជាបានចូលរួមនៅក្នុងការប្រជុំ ហើយនៅក្នុងពេលប្រជុំហ្នឹង គេនិយាយអំពីការបោសសម្អាតផ្ទៃក្នុងនិងការកំណត់មុខសញ្ញាអ្នកណាដែលបានចូលដៃជើងជាមួយនឹងវៀតណាដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលទេបាទ។

**ស៖** ក៏ប៉ុន្តែនេះជាចម្លើយរបស់លោកនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺលោកឆ្លើយនៅទីនេះ <នៅអគារខាងក្រោយសាលសវនាការនេះ>។ លោកចង់កែចម្លើយហ្នឹង ឬក៏យ៉ាងម៉េច? អ្វីដែលលោកឆ្លើយ នៅពេលលោកឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹង មិនត្រឹមត្រូវទេ ឬក៏

យ៉ាងម៉េច?

[០៩:២៩:៤១]

**ឆ៖** ជាការពិត ខ្ញុំមិនដែលបានចូលរួមទេ ប៉ុន្តែបើផ្នែកខាងយោធាគឺខ្ញុំបានចូលរួម តែចំពោះរឿងផ្នែកមូលដ្ឋានដែលខ្ញុំទៅរស់នៅបូព៌ាហ្នឹងគឺមិនមែនរឿងខ្ញុំត្រូវបានគិតពីរឿងទីនោះទេ គឺរឿងគិតតែពីរឿងការច្បាំងជាមួយនឹងវៀតណាមតែប៉ុណ្ណោះទេ។

**ស៖** លោកមានបានចូលរួមការប្រជុំនៅចម្ការកៅស៊ូជុប ដែលមានវត្តមានរបស់ ប៉ុល ពត ទេ?

**ឆ៖** ខ្ញុំគឺជាកងការពារ បានន័យថា ទៅការពារឱ្យបងលេខ១ ហ្នឹង គឺគេចាត់ពួកខ្ញុំហ្នឹងចំនួនប្រហែលជា ខ្ញុំមិនអាចរាប់អស់ទេ ពីព្រោះគេដកពួកខ្ញុំពាក់កណ្ដាលឱ្យទៅ។ មេបញ្ជាការ តាពីន ហ្នឹងគាត់ប្រាប់ថាឱ្យពួក សឿន ឯងទៅពាក់ណ្ដាល បានន័យថាទៅបីកងអនុសេនាតូច ដើម្បីទៅយាមការពារ ថ្នាក់លើគេមកប្រជុំ។ គាត់ប្រាប់ប៉ុណ្ណឹង។

[០៩:៣១:៣២]

**ស៖** នៅចម្លើយទី៦៨ គឺនៅក្នុងឯកសារ E3/9771 ហ្នឹង លោកថា ការប្រជុំហ្នឹងគឺនៅ<ក្នុងខែ ឧសភា> ពាក់កណ្ដាលឆ្នាំ៧៨។ អ៊ីចឹងពេលហ្នឹង តើ ប៉ុល ពត មានបានធ្វើបទឧទ្ទេសនាមអ្វីទេ ហើយបើបានធ្វើ តើលោកបានឮគាត់និយាយអ្វីខ្លះ?

**ឆ៖** បាទ ខ្ញុំនៅឆ្ងាយបន្តិចដែរបាទ មិនសូវជាច្បាស់ មិនឮអីទេ គ្រាន់តែសួរទៅតាមអ្នកដែលគេនៅជិតៗហ្នឹង។ ប៉ុល ពត គាត់បានលើកនិយាយអំពីរឿងព្រំដែន រឿងប្រទេសជាតិ រឿងប្រជាជនដែលត្រូវកងទ័ពវៀតណាមកៀរយកទៅ ឬក៏រឿងអីផ្សេងៗទៀត ខ្ញុំមិនសូវយកចិត្តទុកដាក់ទេពេលនោះបាទ ខ្ញុំគ្រាន់តែសួរគេថាប៉ុណ្ណឹង គេឆ្លើយប្រាប់ប៉ុណ្ណឹងបាទ។

**ស៖** តើលោកដឹងព័ត៌មានពាក់ព័ន្ធនឹងអ្នកដែលអង្គុយជិតគាត់ហ្នឹងទេ ហើយពេលនុ៎ង ប៉ុល ពត គាត់មានបាននិយាយអំពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅទេ?

**ឆ៖** អ្នកដែលនិយាយប្រាប់ខ្ញុំហ្នឹង គាត់អត់និយាយរឿងអីទេ គាត់ថា អត់មានអី ដូចខ្ញុំនិយាយពីមុនអំមិញហ្នឹង តែប៉ុណ្ណឹងទេបាទ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:៣៣:៤៦]

**ស៖** ខ្ញុំមានប្រធានបទពីរទៀត។ ប្រធានបទទី១ ពាក់ព័ន្ធនឹងរយៈពេលដែលលោកនៅកំពង់សោម គឺប្រហែលនៅឆ្នាំ១៩៧៥។ នៅពេលនោះ តើលោកមានដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំ ដែលដឹកនាំ

ដោយ មាស មុត នៅពេលនុ៎ងទេ?

**ឆ៖** ខ្ញុំមិនដែលបានជួប មាស មុត ផ្ទាល់ទេ ពេលទៅ មើលឃើញតែពីចម្ងាយ ក៏ប៉ុន្តែក្នុងការប្រជុំអី ខ្ញុំមិនដែលបានជួបប្រជុំជាមួយ គាមុត នោះទេបាទ។

**ស៖** នៅក្នុងកំណត់ហេតុ E3/9771 នៅចម្លើយទី១២ ខ្ញុំសូមដកស្រង់ឃ្លាមួយជាភាសាអង់គ្លេស។ សូមដកស្រង់៖ "លោកបាននិយាយថា លោកមិនដែលបានចូលរួមវគ្គអប់រំរៀនសូត្រនយោបាយទេ ប៉ុន្តែក្រោយមកនិយាយមិត្តភក្តិខ្ញុំម្នាក់ដែលជាសមាជិកបក្សបាន ដែលបានចូលរួមប្រជុំបាននិយាយគ្នា បាននិយាយប្រាប់ខ្ញុំអំពីខ្លឹមសារនៃអង្គប្រជុំនោះ"។ បញ្ចប់ការដកស្រង់។

[០៩:៣៥:២៦]

លោកអាចជម្រាបបានទេថា មិត្តភក្តិរបស់លោកនោះ បានទៅចូលរួមក្នុងប្រជុំហ្នឹង ហើយបានប្រាប់លោកអំពីខ្លឹមសារនៃបទអន្តរាគមន៍ ដែលលើកឡើងដោយ មាស មុត នៅ<កំពង់សោម?> អ៊ីចឹងអ្វីដែលខ្ញុំចង់ដឹងជាពិសេសនោះ ខ្ញុំចង់ដឹងថា តើ មាស មុត គាត់បាននិយាយអំពីអ្វីខ្លះ ពាក់ព័ន្ធនឹងទាហាន លន់ នល់?

**ឆ៖** បើតាមមិត្តដែលប្រាប់ខ្ញុំនោះ គាត់ មាស មុត គាត់និយាយតែពីរឿងការពារសមុទ្រឲ្យប្រយ័ត្នក្នុងការពារសមុទ្រ ទឹកសមុទ្រហ្នឹង ព្រោះថា មានចោរសមុទ្រលួចអូសត្រីជាបន្តបន្ទាប់ហើយ។ ដូច្នេះគ្រាន់ថា ធ្វើយ៉ាងណាឲ្យចាប់ឲ្យបានកុំសម្លាប់គេ បញ្ជូនទៅក្រុងកំពង់សោម គ្រាន់តែប្រាប់ប៉ុណ្ណឹងបាទ។

**ស៖** ខ្ញុំសូមដកស្រង់នៅចម្លើយរបស់លោក ដែលបានឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺចម្លើយទី១៣ នៃកំណត់ហេតុ E3/9771 ខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស។

"នៅពេលនោះ នៅក្នុងកិច្ចប្រជុំ អង្គការនិងបក្សទាំងអស់បានប្រកាសថា ពួកគាត់<មានផែនការសម្រិតសម្រាំងកងទ័ព។ អង្គការមានផែនការ>បោសសម្អាត<ពួលមូលធន និង>អតីតទាហាន លន់ នល់"។ បញ្ចប់ការដកស្រង់។ លោកអាចបញ្ជាក់បានទេ ត្រង់ចំណុចនេះថា មិត្តភក្តិរបស់លោកហ្នឹង បាននិយាយអំពីចំណុចទាំងអស់ហ្នឹង ប្រាប់លោក?

**ឆ៖** ខ្ញុំមិនអាចឆ្លើយបានទេ ព្រោះអីស្តាប់មិនសូវបានអម្បាញ់មិញ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី អម្បាញ់មិញនេះ ខ្ញុំដកស្រង់ចម្លើយ ដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត លោកថា នៅពេលនោះមិត្តភក្តិរបស់លោក

ម្នាក់បានរៀបរាប់ប្រាប់លោកអំពីសម្ដីរបស់ មាស មុត ដែលបាននិយាយនៅក្នុងពេលប្រជុំនៅកំពង់-សោម។ លោកបានឆ្លើយថា អង្គការបានប្រកាសថា ខ្លួនមានគម្រោងចម្រាញ់ ឬក៏បន្សុទ្ធកងទ័ព ហើយ អង្គការហ្នឹង មានគម្រោងកម្ទេចពួកនាយទុន និងអតីតទាហាននៃរបប លន់ នល់។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើមិត្តភក្ដិរបស់លោកហ្នឹង ពិតជាបាននិយាយចំណុចទាំងអស់ហ្នឹងប្រាប់លោកមែនទេ?

[០៩:៣៨:៥៦]

**ធ៖** មិត្តភក្ដិរបស់ខ្ញុំ គាត់អត់ដែលបាននិយាយទេ ដូចខ្ញុំបញ្ជាក់អ៊ីចឹង។ គាត់មកពីប្រជុំវិញ គាត់ប្រាប់ថា ឲ្យយើងហ្នឹង ការពារទឹកដីសមុទ្រ តែប៉ុណ្ណឹងទេ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី គឺខ្លួនលោកផ្ទាល់ ដែលបានឆ្លើយនៅក្នុងកំណត់ហេតុនេះ ហើយលោកក៏បានចុះហត្ថលេខាទៀត ហើយពេលនុ៎ង គេអានឲ្យលោកស្ដាប់ទៀត មុននឹងឲ្យលោកចុះហត្ថលេខាហ្នឹង។ អ៊ីចឹង ហេតុអីបានជានៅថ្ងៃនេះ លោកផ្លាស់ប្ដូរចម្លើយរបស់លោក?

**ធ៖** ខ្ញុំមិនដែលឆ្លើយអីជាមួយអ្នកណាទេ កាលនោះ គឺខ្ញុំដឹងតែពី ខ្ញុំហ្នឹងទៅនៅជើងទឹក ហើយក៏ទទួលបញ្ជាពីមេបញ្ជាការខ្ញុំមកប្រជុំជាមួយ តាមុត អ៊ីចឹង ហើយគាត់ទៅវិញ គាត់ប្រាប់ថា ឲ្យទៅការពារទឹកដីទេ អារឿងអតីតទាហាន លន់ នល់ ទាហានអី ខ្ញុំមិនដែលបាននិយាយទេ បាទ។

**ស៖** លោកមានបញ្ហាពាក់ព័ន្ធនឹងការចងចាំទេ លោកដើមបណ្ដឹងរដ្ឋប្បវេណី?

**ធ៖** ពិតជាមានមែន គឺថា វារយៈពេលហ្នឹង វាយូរពេកមកហើយ។

**ស៖** ដោយសារតែខ្ញុំនៅសល់ពេលខ្លីណាស់ អ៊ីចឹងខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធនឹងមន្ទីរសន្តិ-សុខក្រាំងតាចាន់។ លោកបាននិយាយជាច្រើនដងថា សមាជិកគ្រួសាររបស់លោកប្រហែលជាត្រូវបានឃុំនៅមន្ទីរក្រាំងតាចាន់។ ឥឡូវខ្ញុំចង់ចាប់ផ្ដើមសួរពាក់ព័ន្ធនឹងឪពុករបស់លោក តើលោកដឹងអ្វីខ្លះពាក់ព័ន្ធនឹងការចាប់ខ្លួនឪពុករបស់លោក ហើយលោកដឹងអ្វីខ្លះពាក់ព័ន្ធនឹងការឃុំខ្លួនរបស់គាត់នៅមន្ទីរក្រាំងតាចាន់?

[០៩:៤១:៤០]

**ធ៖** ខ្ញុំសូមជម្រាបថា នៅពេលឆ្នាំ១៩៧៩ ខ្ញុំបានវិលត្រឡប់ទៅរកឪពុកម្ដាយក្រុមគ្រួសារនៅស្រុកភូមិកំណើតវិញ។ ដល់ពេលខ្ញុំទៅ ខ្ញុំក៏បាត់បង់ឪពុកជាទីគោរពម្នាក់ ដោយគាត់ត្រូវគេជម្លៀសចេញពីខេត្តតាកែវបាទ។ ហើយខ្ញុំសួរសាក បងប្អូនដែលគេដឹង បងប្អូនដែលដឹងថា តើឪពុកខ្ញុំគេចាប់យកទៅទីណា។ គេថា គេប្រាប់ខ្ញុំថា គេចាប់យកទៅលើទៅ។ កាលនោះ មិនបានឮថា ក្រាំងតាចាន់ទេ

គេថា ចាប់យកទៅភ្នំ។ អ៊ីចឹងហើយគេធ្វើទារុណកម្មសួរចម្លើយគាត់រួច បានគេសម្លាប់គាត់នៅក្នុងរយៈឆ្នាំ ចុងឆ្នាំ៧៥ ហ្នឹងបាទ។

**ស៖** ខ្ញុំសូមអានផ្នែកមួយនៃឯកសាររបស់លោក គឺ E319/23.3.42 គឺចម្លើយទី១៦៥ សូមអានជាភាសាអង់គ្លេស។

សូមដកស្រង់ សំណួរទី១៖ "តើមានអ្វីកើតឡើងចំពោះឪពុកម្ដាយរបស់លោក? លោកឆ្លើយថា៖ ក្រោយថ្ងៃទី១៧ មេសា ៧៥ កងទ័ពខ្មែរក្រហម បានជម្លៀសពួកគាត់ចេញពីទីរួមខេត្តតាកែវ។ ឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅមន្ទីរសន្តិសុខក្រាំងតាចាន់ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ ពួកគេចោទឪពុករបស់ខ្ញុំថាជា<>មេ១០០ខ្នង ហើយគាត់ត្រូវបានធ្វើទារុណកម្ម <ទាល់តែស្លាប់>។ ចម្លើយ ១៧០៖ ពួកគេបានសួរចម្លើយគាត់ និងវាយដំគាត់ <រហូតដល់ស្លាប់>។ សំណួរ១៧៤៖ ខ្ញុំក៏បានទទួលព័ត៌មានពីឈ្លបនៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលនិយាយថា ឪពុករបស់ខ្ញុំត្រូវបានគេឃុំខ្លួននៅក្នុងបន្ទប់ខាងក្រោមដី ហើយនិងសម្លាប់នៅទីនោះ"។ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកមានចាំថា លោកបានឆ្លើយចំណុចហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយដល់ចំណុចហ្នឹង។

[០៩:៤៥:១៦]

**ស៖** តើអ្នកណាខ្លះជាអ្នកប្រាប់លោក ថាឪពុកលោកត្រូវបានគេឃុំនៅក្រាំងតាចាន់នោះ? ហើយគេមានបានរៀបរាប់ប្រាប់លោក ឪពុកលោកហ្នឹងស្លាប់យ៉ាងម៉េចទេ?

**ឆ៖** ខ្ញុំសួរបងប្អូនជាច្រើន ដែលគាត់នៅរស់គាត់ដឹង គាត់ប្រាប់ថាជាច្រើននាក់ ខ្ញុំសួរបញ្ជាក់ហើយបញ្ជាក់ទៀតជាមួយបងប្អូននោះ ហើយបងប្អូននោះក៏ប្រាប់ថាវាជាពិតណាស់ គាត់ពិតជាគេយកទៅធ្វើទារុណកម្មនៅក្រាំងតាចាន់ហ្នឹងហើយ សម្លាប់នៅហ្នឹងបានជាមិនឃើញសពគាត់ផង មិនដឹងថាយ៉ាងម៉េច។ ហើយខ្ញុំដូចថាវានិយាយ។ បាទគឺចប់ប៉ុណ្ណឹងបាទ។

**ស៖** ក្រៅពីឪពុករបស់លោក តើមានសមាជិកគ្រួសាររបស់លោកណាខ្លះត្រូវបានឃុំនៅមន្ទីរក្រាំងតាចាន់ តាមការដឹងឮរបស់លោក ក្រោយឆ្នាំ១៩៧៩នោះ?

**ឆ៖** ក៏បានឮថាឪពុកមាបង្កើតរបស់ខ្ញុំម្នាក់ដែរបាទ។

**ស៖** ឪពុកមារបស់លោកហ្នឹងជាកងទ័ព លន់ នល់ ឬក៏គាត់គ្រាន់តែជាប្រជាជនធម្មតា ហើយឬក៏គាត់ចូលរួមតស៊ូដើម្បីបដិវត្តន៍ គាត់ជាមនុស្សប្រភេទណា គាត់មានមុខងារអ្វីដែរ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ គាត់ជាអតីតគ្រូបង្រៀន ហើយគាត់ទៅរស់នៅក្នុងតំបន់សាធារណរដ្ឋលន់ នល់ នោះបាទ។

**ប្រធានអង្គជំនុំ៖**

ពេលវេលាអស់ហើយណា ព្រះរាជអាជ្ញារងអន្តរជាតិ។

បាទ តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ជាដំបូងនេះផ្តល់វេទិកាជូនទៅមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំមិនមានសំណួរទៅសាក្សីនេះទេ ប៉ុន្តែខ្ញុំមានសំណួរមួយទៅអង្គជំនុំជម្រះ។ ហេតុអ្វីបានជ្រើសរើសយកសាក្សីនេះសម្រាប់វគ្គនេះ ទាក់ទងទៅនឹងតួនាទីជនជាប់ចោទ? ពីព្រោះខ្ញុំមិនបានឮសំណួរណាមួយពាក់ព័ន្ធទៅនឹងវិសាលភាពទៅនឹងវគ្គនៃសវនាការនេះទេ។ ខ្ញុំនឹងថ្លែងអំណរគុណបើក្នុងករណីដែលអង្គជំនុំជម្រះបំភ្លឺខ្ញុំពីនីតិវិធីនៃការជ្រើសរើស។ ហេតុអ្វីបានជាកោះអញ្ជើញសាក្សីរូបនេះមកធ្វើសក្ខីកម្មនៅក្នុងវគ្គនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បន្តទៅនេះវេទិកាជូនទៅសហមេធាវីការពារក្តី លោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[០៩:៤៩:២៣]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអង្គជំនុំជម្រះអង្គជំនុំជម្រះ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរលោកបញ្ជាក់បន្ថែម។ មុននេះលោកនិយាយអំពីថាលោកបានដឹងឪពុករបស់លោកស្លាប់ក្រោយឆ្នាំ១៩៧៩តាមរយៈអ្នកភូមិ ឬក៏បងប្អូនរបស់លោក ហើយលោកបានបញ្ជាក់ថា គាត់ស្លាប់នៅក្រាំងតាចាន់។ ខ្ញុំចង់សួរបញ្ជាក់លោកថា នៅក្នុងឯកសារ E3/5979 ដែលជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើកទី១។ លោកបានបញ្ជាក់ស្រដៀងគ្នានេះដែរ ថាលោកបានដឹងក្រោយឆ្នាំ១៩៧៩ ប៉ុន្តែលោកថា ឪពុករបស់លោកហ្នឹង ត្រូវបានជាប់គុកនៅភូមិគុកភ្នំឆ្នារ នៅភូមិភ្នំឆ្នារ ឃុំម្រោម ស្រុកអង្គរជ័យ ខេត្ត កំពត។ អ៊ីចឹង បានន័យថា ទីតាំងពីរ ដែលមួយនៅខេត្តតាកែវ, មួយនៅខេត្តកំពត។ វាខុសគ្នា។ ខ្ញុំចង់ សួរបញ្ជាក់ថា តើលោកមានអ្វី ដែលជាភស្តុតាងជាក់លាក់បញ្ជាក់ពីកន្លែង ដែលឪពុករបស់លោកជាប់ ឃុំឃាំង និងស្លាប់នោះទេ?

[០៩:៥១:១៥]

2-TCCP-235៖

**ឆ៖** បាទ ក្រោយពីឆ្នាំ១៩៧៤ ខ្ញុំបានសួរបងប្អូន តែជាគ្រាដំបូង គឺគាត់ពិតជាជាប់នៅភ្នំឆ្នារ។ បាទនៅភ្នំឆ្នារមែន។ ប៉ុន្តែបន្ទាប់មក គេបញ្ជូនគាត់ចេញ ព្រោះថាស្រុកអង្គរជ័យនោះ គឺគេចាត់ចូលថា នៅក្នុងស្រុកតំបន់១៣ នៅខេត្តតាកែវដែរ កាលសម័យខ្មែរក្រហមនោះ។ ហើយគេបញ្ជូនខ្លួនគាត់ហ្នឹង ទៅក្រាំងតាចាន់ទៅ។ ខ្ញុំដឹង វាច្បាស់ត្រង់បងប្អូនដែលគាត់រស់នៅ គាត់ដឹង គាត់បញ្ជូនទៅក្រាំងតាចាន់ ក្រោយនៅពេលដែលគេសម្លាប់គាត់នោះ មុន។ ហើយក្នុងការសម្លាប់នេះ មិនមែនស្លាប់ដោយសារមុន ៧៥ទេ គឺចុងឆ្នាំ១៩៧៥ ចូល៧៦ ហើយ ត្រូវគេសម្លាប់នោះ។ ត្រូវពួកខ្មែរក្រហមបានសម្លាប់ក្នុងពេល នោះបាទ។ អរគុណ។

**សៈ** បាទ សំណួររបស់ខ្ញុំ ទី១ ខ្ញុំចង់ឲ្យលោកបញ្ជាក់ច្បាស់លាស់ពីអ្នកដែលលោកបានទទួល ព័ត៌មានហ្នឹង។ ទី២ ខ្ញុំចង់សួរលោកថា ចុះហេតុអីបានក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី លើកទី១របស់លោក ធ្វើនៅឆ្នាំ២០០៨ លោកមិនបានរាយការណ៍ពីការដែលឪពុករបស់លោកជាប់ឃុំ ឃាំង និងស្លាប់នៅក្រាំងតាចាន់ ហើយទើបតែក្រោយមកទេ នៅពេលដែលយើងមានសវនាការរឿង ក្រាំងតាចាន់អីហើយនេះ បានចាប់ផ្តើមលោករាយការណ៍ពីក្រាំងតាចាន់នេះ?

**ឆ៖** ដោយដំបូងឡើយ ខ្ញុំមិននឹកស្មានថា នឹងមានតុលាការជាតិ អន្តរជាតិ ចូលរួមយ៉ាងដូច្នេះទេ គឺខ្ញុំចេះតែឲ្យគេសរសេរដាក់ៗអ្នកនោះ វាមានការភាន់ច្រឡំជាច្រើន កាលដំបូងឡើយ គឺពិបាកណាស់។ ខ្ញុំដាក់តាមរយៈអាដហុក ហ្នឹង។ អាដហុក នោះ គាត់សរសេរឲ្យមិនដឹងថា ខុស ឬត្រូវយ៉ាងណាខ្លះ។ តាមតែចម្លើយខ្ញុំនិយាយ គឺវា ទាំង -- គឺថាគ្មានសង្ឃឹមថានឹងរកយុត្តិធម៌ឲ្យបងប្អូនដែលស្លាប់នេះទេ។

[០៩:៥៤:៣៩]

**សៈ** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំអាចសរុបមកវិញថាលោកមិនដឹងច្បាស់ពីទីតាំងពិតប្រាកដ

ដែលឪពុករបស់លោកស្លាប់ ឬក៏ជាប់ឃុំឃាំងនោះទេ។ អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** អារឿងច្បាស់ មិនច្បាស់ ប៉ុន្តែខ្ញុំក៏បានទៅស្រាវជ្រាវមើលកន្លែងក្រាំងតាចាន់ហ្នឹងក៏មិនមានឃើញឈ្មោះឪពុកខ្ញុំ ប៉ុន្តែអ្នកដែលបញ្ជាក់ប្រាប់ខ្ញុំ អ្នកដែលធ្លាប់ -- មនុស្សស្រីទៀតផង ដែលធ្លាប់ជាអ្នកទទួលខុសត្រូវក្នុងគុកហ្នឹង គេថាបញ្ជូនទៅក្រាំងតាចាន់ ព្រោះគាត់នៅរស់ទល់សព្វថ្ងៃនេះ ស្រីហ្នឹងបាទ មនុស្សស្រីផងបាទ។

**ស៖** លោកស្គាល់អត្តសញ្ញាណច្បាស់លាស់ទេ ដែលលោកថាស្រីជាអ្នកទទួលខុសត្រូវនៅគុកក្រាំងតាចាន់ហ្នឹង ទទួលខុសត្រូវយ៉ាងម៉េចដែរ លោកអាចបញ្ជាក់បានទេ?

**ឆ៖** មិនមែនក្រាំងតាចាន់ទេ និយាយអំពីភ្នំភ្នារ អ្នកដែលនៅគ្រប់គ្រងមើលការខុសត្រូវជាមួយនឹងក្នុងគុកភ្នំភ្នារហ្នឹងបាទ។

[០៩:៥៦:១២]

**ស៖** បាទ សូមអរគុណ។ មុននេះ អំមិញលោកឆ្លើយថាឪពុករបស់លោកស្លាប់នៅក្នុងក្រាំងតាចាន់នៅចុងឆ្នាំ៧៥ តើអ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ៗ

**2-TCCP-235៖**

**ឆ៖** បាទ ជាការពិតហើយក្នុង៧០ ចុង៧៥ ៧៦នោះ ដើមឆ្នាំ៧៦ ហ្នឹងបាទ។

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ ពេលខ្ញុំឃើញនៅក្នុងឯកសារដដែល គឺឯកសារ E3/5979 នៅទំព័រចុងក្រោយទី២ លោកបានបញ្ជាក់ថា ឪពុករបស់លោកហ្នឹងជាប់គុកហ្នឹងភ្នំភ្នារ ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពតនៅដើមឆ្នាំ១៩៧៨។ អ៊ីចឹងបើថាឆ្នាំ៧៨ គាត់នៅឯភ្នំភ្នារនោះនៅឡើយ ធ្វើម៉េចបានគាត់មកក្រាំងតាចាន់នៅចុងឆ្នាំ៧៥ កើត? លោកអាចបញ្ជាក់បានទេ?

[០៩:៥៧:៣៤]

**ឆ៖** ប្រហែលជាអ្នកគេសរសេរហ្នឹងវាច្រឡំបាទ វាច្រើនពេក បាទ គេច្រឡំហើយ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងបងប្អូនបីនាក់របស់លោក បងប្អូនប្រុសបីនាក់ដែលលោកបញ្ជាក់ថាបានស្លាប់ ហើយលោកបានបញ្ជាក់ថាពួកគាត់ជាទាហាន។ តើអ៊ីចឹងត្រឹមត្រូវទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ពីរនាក់ ម្នាក់គឺច្បាស់ជាទាហាន ម្នាក់ទៀតក៏ជា គេហៅថាមន្ត្រីរាជការរបបសាធារណរដ្ឋ លន់ នល់ នោះ។ ហើយម្នាក់ទៀត មកក្រុមគ្រួសារម្នាក់ទៀតគឺគាត់រស់នៅក្នុងខេត្តបាត់ដំបងនៅក្នុងតំបន់សាធារណរដ្ឋ សាធារណរដ្ឋខ្មែរហ្នឹង រហូតគឺគាត់ជាអ្នកធ្វើស្រែចម្ការទេបាទ គាត់ជា--

**ស៖** លោកអាចបញ្ជាក់ម្តងទៀតឲ្យច្បាស់ ថាអ្នកណាអ្នកធ្វើស្រែចម្ការ ឈ្មោះអីដែរ បងប្អូនប្រុសហ្នឹង?

**ឆ៖** បង អ៊ូ ខ្ញុំបាទ។

**ស៖** អ៊ីចឹងគាត់ជាបងទី២ របស់លោក ត្រឹមត្រូវទេ?

**ឆ៖** ទី៣--

**ប្រធានអង្គជំនុំ៖**

កុំអាល់ទាន់ឆ្លើយ។

**2-TCCP-235៖**

**ឆ៖** បាទ ទី២ បាទ។

[០៩:៥៩:២៧]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ បាទ ក្នុងឯកសារ E3/5979 ដដែលនេះក្នុងទំព័រនៅផ្នែក(គ) លោកបានបញ្ជាក់បងប្អូនប្រុសទាំងបីនាក់របស់លោកហ្នឹង សុទ្ធតែជាកសិករទាំងអស់ តែអ្នកធ្វើស្រែ មុខរបរធ្វើស្រែទាំងអស់។ ហេតុអីបានមានភាពខុសគ្នាបែបនេះ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ព្រោះពេលនោះ ខ្ញុំនឹកឃើញថាក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងសុទ្ធសឹងជាអ្នកធ្វើទៅធ្វើស្រែចម្ការអស់ហើយ ទាំងអស់ហ្នឹង ខ្ញុំដាក់អ៊ីចឹង។

**ស៖** លោកអាចបញ្ជាក់ថា បងៗរបស់លោកហ្នឹងធ្វើជាទាហានប៉ុន្មានឆ្នាំដែរ ក្នុងម្នាក់ៗលោកចាំបានទេ? អាចចាប់ផ្តើមពីបងទី១។

**ឆ៖** បងបន្ទាប់របស់ខ្ញុំគឺឈ្មោះ អ៊ូ ដាន់ គាត់ចូលធ្វើទាហានសាធារណរដ្ឋខ្មែរហ្នឹង គឺពីឆ្នាំ ១៩៧០ ហើយបងបង្អស់ឈ្មោះ អ៊ូ ញ៉ន គាត់ជាអតីតគ្រូបង្រៀន ហើយនៅពេលនោះបង្រៀននៅខេត្តតាកែវទេ ប៉ុន្តែដល់ពេលគាត់របបក្រោយពីរដ្ឋប្រហារ គាត់ក៏បានភៀសទៅក្រុម នៅនាំក្រុមគ្រួសារគាត់ទៅនៅក្រុងភ្នំពេញ។ ហើយខ្ញុំក៏បានដឹងគាត់ថា គាត់នៅធ្វើជាកងជើងទឹកទន្លេសាបនៅជ្រោយចង្វារ

ហ្នឹង។ ហើយបងទី២ ឈ្មោះ អ៊ូ ញ៉ុង នោះគាត់អត់បានធ្វើអីទេ គាត់ធ្វើស្រែចម្ការនៅខេត្តបាត់ដំបង។ នេះខ្ញុំបញ្ជាក់ជាការពិតតែប៉ុណ្ណឹងទេ។

[១០:០២:២៧]

**ស៖** បាទ សូមអរគុណ។ ទាក់ទងម្ដាយរបស់លោក គាត់នៅជាប់ឃុំនៅភូមិភ្នំឆ្នារដែរ ឬមួយក៏លោកមិនមានព័ត៌មានទាក់ទងចំណុចនេះទេ?

**ឆ៖** ម្ដាយរបស់ខ្ញុំ គាត់គឺរស់នៅក្នុងសហករណ៍ បានន័យថា ហើយក៏គេចាត់ទុកថាជាក្រុមគ្រួសារខ្មាំង។ អ៊ីចឹងគេឲ្យគាត់នៅក្នុងសហករណ៍ហ្នឹងដែរ គេឲ្យធ្វើការងារធ្ងន់ៗជាងគេ។ បាទ អាហ្នឹងខ្ញុំសូមជម្រាប។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ជាចុងក្រោយនៃការផ្ដល់សក្ខីកម្មរបស់លោកក្នុងឋានៈលោកជាដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពអន្តរាយដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

[១០:០៤:១៦]

**2-TCCP-235៖**

ខ្ញុំសូមថ្លែងអំណរអរគុណដល់លោកប្រធាន ប្រធានអង្គជំនុំជម្រះ ដែលបានអនុញ្ញាតឲ្យខ្ញុំបាទបានឡើងថ្លែងនូវព្យសនកម្មរបស់ខ្ញុំ ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី។

ខ្ញុំសូមជម្រាបដូចតទៅ នៅក្នុងឆ្នាំមួយពាន់ -- ប្រហែលជា៧នាទីយ៉ាងយូរបាទ សូមជម្រាប នៅឆ្នាំ១៩៧០ ខ្ញុំបាទបួសនៅវត្តច្រាប តំបន់ជនបទ។ នៅឆ្នាំ១៩៧១ កងឈ្លបរបស់អង្គការបដិវត្តន៍ គេបង្ខំឲ្យសឹក រួចគេចាប់បញ្ជូនឲ្យទៅធ្វើកងទ័ពបដិវត្តន៍។ ខ្ញុំបានរៀនសូត្រហាត់ពត់លត់ដំ ដើរតាមមាគ៌ានយោបាយរបស់អង្គការបក្សបដិវត្តន៍ ទោះជាត្រូវស្ដាប់របួសធ្ងន់ ស្រាល សន្លប់ កប់ក្នុងត្រង់សេ ត្រូវផ្សែងពុល ក្ដៅ រងា ញាក់ញ័រ សន្លប់រាប់មិនអស់យ៉ាងណាក្ដី ខ្ញុំនៅតែដើរតាមអង្គការបក្សបដិវត្តន៍

ជានិច្ច។

ក្រោយពីទទួលបានជ័យជម្នះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវរបបកម្ពុជាប្រជាធិបតេយ្យដកពីជួរកងទ័ពបញ្ជូនឲ្យទៅធ្វើការជាទម្ងន់នៅតំបន់១១ ខេត្តកោះកុង។ ជាប់គុកឥតជញ្ជាំងអស់រយៈ១៣ខែ។ នៅជាងពាក់កណ្ដាលឆ្នាំ១៩៧៧ គេបញ្ជូនខ្ញុំឲ្យទៅច្បាំងជាមួយវៀតណាមនៅទិសបូព៌ាអស់រយៈ១៦ខែ។

ក្រោយពីឆ្នាំ១៩៧៩ ខ្ញុំបានវិលត្រឡប់មករកឪពុកម្ដាយ បងប្អូនសាច់ញាតិនៅស្រុកភូមិកំណើតវិញ ខ្ញុំមានការសោកស្ដាយឈឺចាប់ជាទីបំផុត ដោយការបាត់បង់លោកឪពុកអ្នកម្ដាយជាទីគោរពបំផុត។ ឪពុកធំ ឪពុកមា ម្ដាយមីងបង្កើត បងៗបង្កើត ក្មួយៗបង្កើតទាំងបីគ្រួសារ ត្រូវដាច់ពូជសរុបម្ភៃជាងនាក់ ដែលត្រូវរបបកម្ពុជាប្រជាធិបតេយ្យចាប់យកទៅធ្វើទារុណកម្ម រួចសម្លាប់ចោលទាំងអស់។ នៅពេលខ្ញុំនឹកឃើញម្ដងៗមានការឈឺចាប់ទាំងផ្លូវចិត្តទាំងរូបកាយ បាក់ស្បាតជារៀងរហូតមក។

[១០:០៧:៤៣]

នៅពេលមានតុលាការជាតិ អន្តរជាតិ ខ្ញុំក៏ដាក់ពាក្យបណ្ដឹង ជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីរកយុត្តិធម៌ជូនដល់លោកឪពុកម្ដាយបងប្អូនសាច់ញាតិ ព្រមទាំងបងប្អូន២លាននាក់ជាងនោះ ដែលត្រូវស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ។

ខ្ញុំសូមអរគុណបាទ ប៉ុន្តែនៅមានបន្តសំណួរបន្តិចទៀតបាទ។ តើលោកប្រធានអនុញ្ញាតទេ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយសូមលោកសួរទៅឆ្ពោះទៅរកជនជាប់ចោទ គ្រាន់តែធ្វើតាមរយៈប្រធាន មិនអាចសួរផ្ទាល់បានទេ ប៉ុន្តែមិនឲ្យមកសួរប្រធានទេ ព្រោះប្រធានមិនមានភារកិច្ចឆ្លើយតបនឹងសំណួរលោកទេ គឺជនជាប់ចោទទេ ដែលគាត់មានភារកិច្ចឆ្លើយតប ប៉ុន្តែនីតិវិធីតម្រូវឲ្យសួរលោកតាំងសំណួរហ្នឹងតាមរយៈប្រធានអង្គជំនុំជម្រះ។

[១០:០៨:៥៨]

**2-TCCP-235៖**

សំណួររបស់ខ្ញុំពីរខ្លីបាទ។ ខ្ញុំបាទ តាមសួរតាមរយៈលោកប្រធានអង្គជំនុំជម្រះ។ ទី១ ខ្ញុំបាទខំគោរពដើរតាមមាគ៌ានយោបាយរបស់បក្ស លះបង់អាយុជីវិត មិនដែលគិតថា ត្រូវស្លាប់ថ្ងៃណាឡើយ។ នៅពេលរបបកម្ពុជាប្រជាធិបតេយ្យបានកើតឡើង តើហេតុអីបានជាចាប់ឪពុកម្ដាយសាច់ញាតិបង្កើតរួមទាំងរូបខ្ញុំ និងយុទ្ធមិត្តជាច្រើននាក់ទៅធ្វើទារុណកម្ម រួចសម្លាប់ដាក់គុកបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អាហារមិនដែលគ្រប់គ្រាន់ ហើយត្រូវដកបាត់ខ្លួនជាបន្តបន្ទាប់? ម្តេចក៏ទៅជាបែបនេះទៅវិញ?

សំណួរពីរ ខ្ញុំបាទ បានឮតាមវិទ្យុប្រកាសនៅរបបកម្ពុជាប្រជាធិបតេយ្យនេះ ល្អណាស់ ហើយខ្ញុំបានស្តាប់តាមវិទ្យុប្រកាសដោយលោក ខៀវ សំផន ថា របបអង្គរមួយកំប៉ុងកន្លះទៅពីរកំប៉ុងក្នុង១ថ្ងៃសម្រាប់ប្រជាជនទូទៅម្នាក់ៗ។ ជាការពិតប្រជាជនក្មេង ចាស់ ប្រុសស្រី នៅតាមភូមិឃុំសហករណ៍នានា ស្ទើរតែទាំង ទូទាំងប្រទេសឲ្យហូបតែបបរាវៗទៅវិញ តើហេតុអីទៅវិញ?

បាទ អរគុណ ហើយបាទអរគុណមិនមានសំណួរអីទៀតទេ ប៉ុន្តែនឹងនៅគ្រាចុងក្រោយខ្ញុំនឹងសូមអរគុណនៅមួយចំណុចបន្តិចទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកដើមបណ្តឹង។ អង្គជំនុំជម្រះសូមជម្រាបលោកដើមបណ្តឹងរដ្ឋប្បវេណីថា នៅក្នុងកិច្ចដំណើរការសវនាការអង្គសេចក្តីពិនិត្យភស្តុតាងក្នុងសំណុំរឿង ០០២/០២ តាំងពីដើមដំបូងទីនៃសវនាការជនជាប់ចោទទាំងពីរ នួន ជា និង ខៀវ សំផន បានឆ្លើយថា គាត់អនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួររបស់ភាគី ឬចៅក្រមនៃអង្គជំនុំជម្រះ ហើយនៅក្នុងសវនាការកាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ជនជាប់ចោទ ទាំងពីររូបឆ្លើយបញ្ជាក់អំពីការដែលពួកគាត់នៅតែបន្តរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបនឹងសំណួរ ហើយរហូតមកដល់ពេលនេះ អង្គជំនុំជម្រះមិនទាន់បានទទួលដំណឹងពីការផ្លាស់ប្តូរជំហររបស់គាត់ជនជាប់ចោទទាំងពីររូប ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀមមិនឆ្លើយតបមកយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។

[១០:១១:៥០]

បាទ ជាវិធានច្បាប់ទាំងជាតិ និងអន្តរជាតិ គឺអង្គជំនុំជម្រះមិនអាចបង្ខំឲ្យជនជាប់ចោទឆ្លើយតបនឹងសំណួរបានទេ កាលបើគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប ដូចមានចែកនៅក្នុងវិធានបញ្ញត្តិដែលអនុវត្តសម្រាប់នៅ អ.វ.ត.ក នេះ។ ហើយចុងក្រោយនេះ លោកមានអីបន្តិចទៀតហ្នឹង លោកអាចនិយាយបាន លោកចង់និយាយរឿងអីទៅ?

**2-TCCP-235៖**

បាទ ខ្ញុំសូមគោរពដល់អង្គជំនុំជម្រះទាំងអស់ ទាំងមូល។ ខ្ញុំនឹងលើកឡើងនៅគ្រាចុងក្រោយនេះបាទ។ រឿងរ៉ាវម្តៃសាមសិបឆ្នាំកន្លងមកហើយនោះ ដែលខ្ញុំបានលើកឡើងជាការសំខាន់ ទុកជាគំរូដល់មហាជន យុវជន ក្មេងៗជំនាន់នេះ និងជំនាន់តៗទៅ។ អរព្រះគុណ និងអរគុណ។ បាទតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី សវនាការស្តាប់សក្ខីកម្ម និងសេចក្តីថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកលំបាកវេទនា និងស្ថានភាពព្យសនកម្មក្នុងឋានៈលោកជាដើមបណ្តឹងរដ្ឋប្បវេណី ដែលលោកបានអះអាងថា បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ឥឡូវនេះដល់ទីបញ្ចប់ហើយ។ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ នាពេលនេះ គឺវត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណា ដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

[១០:១៣:៥៥]

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់ចង់មានបំណងចង់ទៅបានហើយ។

ហើយសវនាការនៅថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកបន្តធ្វើនៅថ្ងៃទី -- ថ្ងៃចន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក ហើយសវនាការនៅថ្ងៃចន្ទ ទី២១ និងថ្ងៃអង្គារ ទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-223 នៅពេលព្រឹក និងនៅពេលរសៀលស្តាប់សក្ខីកម្មសាក្សី 2-TCW-842 តាមរយៈប្រព័ន្ធសោតទស្សន៍ពីទីក្រុងប៉ារីស ប្រទេសបារាំង និងមានសាក្សីបម្រុង 2-TCW-871។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប និងសាក្សីពីរនេះនឹងផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ ទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃចន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១០:១៥ នាទី)*

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*